# លិខិតអនុញ្ញាតពីឪពុកម្ដាយដើម្បីចូលរួមក្នុងការស្រាវជ្រាវ

អ្នកត្រូវបានស្នើសុំដើម្បីអនុញ្ញាតឱ្យកូនអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ។ មុននឹងអ្នកយល់ព្រម អ្នកនឹងត្រូវបានជម្រាបជូនឱ្យដឹងអំពីខ្លឹមសារសង្ខេបនៃការសិក្សាស្រាវជ្រាវនេះ។ ខ្លឹមសារសង្ខេបនេះ មានព័ត៌មានសំខាន់ៗ ដើម្បីជួយអ្នកឱ្យយល់អំពីហេតុផលថាតើអ្នកចង់ ឬមិនចង់ចូលរួមការសិក្សាស្រាវជ្រាវនេះ។

មុននឹងអ្នកយល់ព្រម អ្នកអង្កេតត្រូវប្រាប់អ្នកអំពីៈ

(១) គោលបំណង ដំណើរការ និងរយៈពេលនៃការស្រាវជ្រាវ,
(២) ផ្នែកណាមួយដែលមានលក្ខណៈពិសោធន៍,
(៣) ហានិភ័យណាមួយដែលអាចប្រមើលមើលឃើញ ភាពមិនស្រួល និងអត្ថប្រយោជន៍នៃការស្រាវជ្រាវ,
(៤) នីតិវិធី ឬដំណោះស្រាយណាមួយដែលមានអត្ថប្រយោជន៍ជាង,
(៥) របៀបរក្សាការសម្ងាត់ និង
(៦) អ្នកណាដែលអាចទាក់ទងបាននៅពេលដែលអ្នកមានចម្ងល់ ពាក្យបណ្ដឹង និងការរងគ្រោះផ្សេងៗ។

បើពាក់ព័ន្ធត្រង់កន្លែងណាមួយ អ្នកអង្កេតត្រូវប្រាប់អ្នកផងដែរអំពីៈ

(១) សំណងជំងឺចិត្ត ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រណាមួយដែលមាន ប្រសិនបើមានរបួសកើតឡើង,
(២) លទ្ធភាពអាចកើតឡើងនូវហានិភ័យដែលមិនអាចប្រមើលមើលឃើញ,
(៣) កាលៈទេសៈនៅពេលអ្នកអង្កេតអាចបញ្ឈប់ការចូលរួមរបស់អ្នក,
(៤) ការចំណាយបន្ថែមណាមួយចំពោះអ្នកឬកូនរបស់អ្នក;
(៥) នឹងមានអ្វីកើតឡើងប្រសិនបើអ្នកសម្រេចចិត្តបញ្ឈប់ការចូលរួមរបស់កូនអ្នក;
(៦) នៅពេលដែលអ្នកនឹងត្រូវបានប្រាប់អំពីការរកឃើញថ្មីដែលអាចជះឥទ្ធិពលដល់ឆន្ទៈរបស់អ្នកដើម្បីអនុញ្ញាតឱ្យកូនអ្នកចូលរួម;
(៧) ចំនួនអ្នកចូលរួមក្នុងការសិក្សា និង
(៨) របៀបដែលអ្នកត្រូវផ្ដល់សិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានវេជ្ជសាស្ត្ររបស់កូនអ្នកសម្រាប់ការសិក្សា។

ការចូលរួមរបស់កូនអ្នកនៅក្នុងការស្រាវជ្រាវនេះគឺជាការស្ម័គ្រចិត្ត ហើយកូនរបស់អ្នកនឹងមិនត្រូវបានពិន័យឬបាត់បង់អត្ថប្រយោជន៍ទេ ប្រសិនបើអ្នកបដិសេធមិនអនុញ្ញាតឱ្យកូនអ្នកចូលរួម ឬសម្រេចចិត្តបញ្ឈប់។ ការចុះហត្ថលេខាលើឯកសារនេះមានន័យថាការសិក្សាស្រាវជ្រាវ រួមទាំងព័ត៌មានខាងលើ ត្រូវបានរៀបរាប់ជូនអ្នកដោយផ្ទាល់មាត់ ហើយអ្នកស្ម័គ្រចិត្តយល់ព្រមអនុញ្ញាតឱ្យកូនអ្នកចូលរួម។ ប្រសិនបើអ្នកយល់ព្រមអនុញ្ញាតឱ្យកូនអ្នកចូលរួម អ្នកត្រូវបានផ្ដល់នូវច្បាប់ចម្លងនៃឯកសារដែលបានចុះហត្ថលេខារួចរាល់ និងសេចក្ដីសង្ខេបជាលាយលក្ខណ៍អក្សរនៃការស្រាវជ្រាវជាភាសាអង់គ្លេស។

**សំណួរ?**

ប្រសិនបើអ្នកមានចម្ងល់ ពាក្យបណ្តឹង របួស ឬក្តីបារម្ភ អំពីការសិក្សានេះ អ្នកអាចទាក់ទងមកកាន់អ្នកអង្កេតដោយប្រើប្រាស់លេខទូរស័ព្ទដែលមាននៅក្នុងខ្លឹមសារសង្ខេបនៃការសិក្សាស្រាវជ្រាវនេះ។ ប្រសិនបើអ្នកមានសំនួរទាក់ទងនឹងសិទ្ធិរបស់កូនអ្នកក្នុងនាមជាអ្នកចូលរួមក្នុងការស្រាវជ្រាវ ឬប្រសិនបើអ្នកមានសំណួរ បណ្តឹង ឬការព្រួយបារម្ភនានា ដែលអ្នកមិនមានអារម្មណ៍ថាអ្នកអាចពិភាក្សាជាមួយអ្នកអង្កេតបាន សូមទាក់ទងមកការិយាល័យគណៈកម្មការពិនិត្យឡើងវិញនូវក្រមសីលធម៌លើការស្រាវជ្រាវ (IRB) នៃវិទ្យាស្ថានសាកលវិទ្យាល័យយូថាហ៍ តាមរយៈលេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីម៉ែលនៅក្នុងសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរនៃការសិក្សាស្រាវជ្រាវនេះ។

____________________
ឈ្មោះកូន

| ____________________ | ____________________ | ____________________ |
| --- | --- | --- |
| ឈ្មោះឪពុកឬម្តាយ/អាណាព្យាបាល | ហត្ថលេខាឪពុកឬម្តាយ/អាណាព្យាបាល | ថ្ងៃខែឆ្នាំ |

____________________
ទំនាក់ទំនងរវាងកុមារនិងឪពុកឬម្តាយ/អាណាព្យាបាល

ខ្ញុំសូមអះអាងថា ខ្ញុំពិតជាមានវត្តមានជាអ្នកបកប្រែក្នុងអំឡុងពេលនៃដំណើរការចុះកិច្ចព្រមព្រៀងសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមានសមត្ថភាព និងជំនាញដែលត្រូវការចាំបាច់គ្រប់គ្រាន់ដើម្បីផ្តល់នូវការបកប្រែរវាងភាសារបស់ឪពុកឬម្តាយ/អាណាព្យាបាល និងភាសាអង់គ្លេស។ តាមរយៈការចុះហត្ថលេខាលើសំណុំបែបបទនេះ ខ្ញុំសូមអះអាងថា ខ្ញុំបានផ្តល់នូវការបកប្រែដោយពេញលេញមួយនូវការផ្លាស់ប្តូររវាងអ្នកស្រាវជ្រាវដែលទទួលបានការព្រមព្រៀង និងឪពុកឬម្តាយ/អាណាព្យាបាលរបស់អ្នកចូលរួម អស់ពីសមត្ថភាពរបស់ខ្ញុំពិតមែន។

| ____________________ | ____________________ | ____________________ |
| --- | --- | --- |
| ឈ្មោះអ្នកបកប្រែ | ហត្ថលេខារបស់អ្នកបកប្រែ | ថ្ងៃខែឆ្នាំ |